# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## កិច្ចប្រជុំលើកទី៥របស់ក្រុមការងាររេដបូកកម្ពុជា

ឆ្នាំពីរពាន់ដប់បួន ខែមិថុនា ថ្ងៃទីប្រាំមួយ វេលាម៉ោងប្រាំបី និងសាមសិបនាទី នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ មានបើកកិច្ចប្រជុំលើកទី៥ក្រុមការងាររេដបូកកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ និងជាប្រធានក្រុមការងាររេដបូកកម្ពុជា។ កិច្ចប្រជុំនេះរៀបចំឡើងដោយលេខាធិការដ្ឋានរេដបូក ដោយមានអ្នកចូលរួមសរុបចំនួន ៣០នាក់ រួមមាន៖ សមាជិកក្រុមការងាររេដបូក ០៨នាក់ តំណាងជំនួសសមាជិកក្រុមការងាររេដបូក ០១នាក់ អ្នករៀបចំមកពីលេខាធិការដ្ឋានរេដបូក ០៨នាក់ និងអ្នកចូលរួមគាំទ្រដទៃទៀតចំនួន ១៣នាក់។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០២)

### មតិចាប់ផ្តើមបើកអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាង ស្វាគមន៍សមាជិកដែលបានចូលរួម និងបើកកិច្ចប្រជុំដោយចាប់ផ្តើមពិនិត្យទៅលើរបៀបវារៈនៃកិច្ចប្រជុំលើកទី៥នេះ។

### បទបង្ហាញ និងកិច្ចពិភាក្សា

### *១-វឌ្ឍនភាពនៃការសម្រេចរបស់កិច្ចប្រជុំលើកទី៤*

លោក លន់ គឹមហ៊ី បានជម្រាបជូនអង្គប្រជុំថា: ១) ការបង្កើតក្រុមយេនឌ័រ: កញ្ញា ធី ហៀង នឹងបង្ហាញជូនអង្គប្រជុំនៅក្នុងរបៀបវារៈខាងមុខ។ ២) ការបកប្រែឯកសារសង្ខេបការសម្រេចស្តីពីរេដរបស់ COP លេខាធិការដ្ឋាននៅមិនទាន់រកបានអ្នកបកប្រែនៅឡើយ ដោយសារឯកសារមានពាក្យលំបាកក្នុងការបកប្រែជាភាសាខ្មែរ។ ៣) ការគាំទ្រចំណាយទំនាក់ទំនងក្រុមបច្ចេកទេស: ចាប់ពីខែឧសភាតទៅ ក្រុមបច្ចេកទេសជាមន្ត្រីរដ្ឋាភិបាល សហគមន៍ និងជនជាតិដើមភាគតិច ទទួលបានកាតទូរស័ព្ទ ៣០ដុល្លារ ម្នាក់ក្នុង១ខែ។ ចំពោះការគាំទ្រចំណាយទំនាក់ទំនងក្រុមការងាររេដបូក នឹងត្រូវធ្វើការចរចាបន្ត។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៣)

ការពិភាក្សា៖

ឯ.ប. ជា សំអាង៖ ឯកសារសង្ខេបសេចក្តីសម្រេចស្តីពីរេដរបស់COPពាក់ព័ន្ធនឹងការងារបច្ចេកទេស និងពាក្យច្បាប់ ដែលមានអត្ថន័យជ្រាលជ្រៅលំបាកយល់ ដូច្នេះការរកអ្នកបកប្រែបានប្តូរពីមួយទៅមួយ។

យើងនឹងព្យាយាមរកអ្នកបកប្រែឲ្យបាន ពីព្រោះឯកសារនេះមានសារសំខាន់ ដែលត្រូវស្វែងយល់។ បើយើងរកអ្នកបកប្រែបាន យើងនឹងអាចធ្វើបច្ចុប្បន្នភាពឯកសារនេះរៀងរាល់ឆ្នាំ។

**ការសម្រេចៈ**

- លេខាធិការដ្ឋានត្រូវបន្តរកអ្នកបកប្រែឯកសារសម្រេច COPនេះ។

ឯ.ឧ. ជា សំអាងៈ បញ្ហា DSA និងការគាំទ្រចំណាយទំនាក់ទំនង មានការលំបាកក្នុងការសម្រេច។ បច្ចុប្បន្នយើងកំពុងចរចារជាមួយ UNDP ជាពិសេស DSA សម្រាប់បេសកម្មនៅតាមបណ្តាខេត្តនានាក្នុងប្រទេស។ អនុក្រិតលេខ១០ កំណត់អត្រា១៥.៧៥ដុល្លារសម្រាប់មន្ត្រីធម្មតា ប៉ុន្តែបច្ចុប្បន្នយើងយកអត្រាអតិបរមាគឺ ៣១.៥០ ដុល្លារ។ ឯកឧត្តមសុំឲ្យក្រុមការងារគាំទ្រ និងចូលរួមទទួលខុសត្រូវលើការអនុវត្តនេះ។

លោក គឹម ណុងៈ ការកំណត់អត្រា DSA មនុស្សយើងជាអ្នកកំណត់ ដូច្នេះត្រូវគិតគូរដល់អ្នកអនុវត្តនិងតម្រូវការជាក់ស្តែង បើមិនដូច្នោះទេការងារនឹងមិនដំណើរការទៅមុខឡើយ។ លោកគាំទ្រការអនុវត្តរបស់ឯកឧត្តមប្រធាន ដែលយកអត្រា DSA អតិបរមា (៣១.៥០ ដុល្លារ) សម្រាប់មន្ត្រីធម្មតាដែលចុះបេសកម្មទៅតាមបណ្តាខេត្តដើម្បីបំពេញការងារកម្មវិធី។ លោកធ្លាប់បានបញ្ជាក់ច្បាស់បញ្ហានេះជាមួយឯកឧត្តមរដ្ឋមន្ត្រីបរិស្ថាន ពីស្ថានភាពដែលមន្ត្រីមិនអាចទទួលយកបានក្នុងអនុវត្តអត្រា១៥.៧៥ដុល្លារ។

**ការសម្រេចៈ**

- ឯ.ឧ. ជា សំអាងនឹងបន្តចរចារជាមួយនឹង UNDP លើបញ្ហាអត្រា DSA នេះដើម្បីឲ្យអ្នកអនុវត្តគម្រោងកម្មវិធីមានសុវត្ថិភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។

## ២. ប្រធានបទពិភាក្សា

### ២.១. ផែនការរៀបចំយុទ្ធសាស្ត្រវេជបូកជាតិកម្ពុជា

លោក ងួន ភក្តី បានធ្វើបទបង្ហាញពីស្ថានភាពនៃការរៀបចំយុទ្ធសាស្ត្រវេជបូកជាតិ ដោយផ្តោតសំខាន់លើ: ១)អ្វីទៅជាយុទ្ធសាស្ត្រវេជបូកជាតិ? ២)សង្ខេបពីការរៀបចំយុទ្ធសាស្ត្រវេជបូកជាតិ៣)ជំពូកនានាដែលបានស្នើឡើងសម្រាប់យុទ្ធសាស្ត្រវេជបូកជាតិ ៤)ពេលវេលារៀបចំយុទ្ធសាស្ត្រវេជបូកជាតិ៥)ទស្សនវិស័យនាពេលអនាគត និង៥)កិច្ចប្រជុំកំពូលស្តីពីអាកាសធាតុអង្គការសហប្រជាជាតិ។ លោក ងួន ភក្តី បានបញ្ជាក់ថាជំពូកទាំង១២ដែលបានស្នើឡើងសម្រាប់យុទ្ធសាស្ត្រវេជបូកជាតិ គឺផ្អែកតាមការសិក្សាយុទ្ធសាស្ត្រវេជបូករបស់ប្រទេសនានានឹងសុំការផ្តល់យោបល់។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៤)

**ការពិភាក្សាៈ**

ឯ.ឧ. ជា សំអាងៈ ការរៀបចំឲ្យមានយុទ្ធសាស្ត្រវេជបូកជាតិ នឹងផ្តល់ឱកាសឲ្យយើងអាចបង្ហាញយុទ្ធសាស្ត្រនេះនៅក្នុងកិច្ចប្រជុំCOPទី២១ ដែលកិច្ចប្រជុំលើកនេះមានភាពប្រាកដប្រជាក្នុងការគាំទ្រវេជបូក។ លើសពីនេះវេជបូកកម្ពុជាត្រូវឈានទៅដល់ជំហានទី២ ដែលត្រូវទទួលបាននូវការគាំទ្រពីប្រទេសដែលមានភារកិច្ចគាំទ្រអនុវត្តវេជបូក។ ប្រសិនបើមានការអូសបន្លាយពេល យើងនឹងបាត់បង់ឱកាស។ បើយើង

រៀបចំបានយុទ្ធសាស្ត្រនេះ ជំហានទី២នៃការអនុវត្តរេដបូកនឹងអាចដំណើរការទៅមុខដោយពុំមានភាពរអាក់រអួល ឬ អសកម្ម។ ប្រទេសណ័រវេសមានថវិកា ដែលទំនង ជាប្រទេសជាប់ភារកិច្ចជាមួយUNFCCC ក្នុងការគាំទ្ររេដបូក។ ជំហ៊ានទី២នេះគឺការសាកល្បងអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិនៅទីវាល។ ជាក់ស្តែងប្រទេសវៀតណាម បានទទួលថវិកាពី UN-REDD ៣០លាន ដុល្លា និងបានពីប្រទេសណ័រវេស ៧០លានដុល្លារក្នុងការអនុវត្តជំហានទី២នេះ។ លទ្ធផលដែលកម្ពុជាយើងសម្រេចបានកន្លងមក មានការពេញចិត្តពីដៃគូផ្តល់ជំនួយ ដូច្នេះនៅពេលដែលយើងរៀបចំបានយុទ្ធសាស្ត្ររេដបូកជាតិ យើងសង្ឃឹមថានឹងមានការគាំទ្រថវិកាមិនក្រោម៥០លាន ឬ លើសពីនេះរហូតដល់១០០លាន។ មាតិកាដែលបង្ហាញនេះ យើងបានសិក្សានិងទាញយកបទពិសោធន៍ដែលបានរៀបចំយុទ្ធសាស្ត្ររេដបូកនៅប្រទេសនានា និងសិក្សាពីបរិបទរបស់ប្រទេសកម្ពុជា និងសកម្មភាពដែលយើងកំពុងធ្វើបច្ចុប្បន្ននេះ ដើម្បីអាចឆ្លើយតបបានទាំងស្ថានភាពក្នុងប្រទេស និងសាកលលោកស្តីពីរេដបូក និងអាចទទួលបានជំនួយយកមកអនុវត្ត។

ឯ.ឧ នេត មុន្នី៖ គាំទ្រការខិតខំរបស់លេខាធិការដ្ឋាន ដែលបានខិតខំដកស្រង់បទពិសោធន៍ពីប្រទេសនានាដើម្បីរៀបចំឯកសារសំខាន់នេះ។ មាតិកាយុទ្ធសាស្ត្ររេដបូកជាតិដែលមាន១២ជំពូកដូចបានបង្ហាញនេះមានភាពទូលំទូលាយ ដូច្នេះក្រុមការងារមានការលំបាកនឹងផ្តល់យោបល់ឲ្យបានជាក់លាក់។ បើអាចធ្វើទៅបានគួរបន្ថែមចំណុចលំអិតថាមានអ្វីខ្លះនៅក្នុងជំពូកនីមួយៗ ដើម្បីឲ្យក្រុមការងារអាចយល់បានល្អប្រសើរជាងនេះ។

លោកបណ្ឌិត ដោក ដូម៉ា៖ លោកបានពិនិត្យឃើញថានៅខ្វះជំពូកមួយទៀតដែលគួបញ្ចូលបន្ថែម គឺជំពូកដែលបង្ហាញពីបញ្ហា និងហេតុផលនានាដើម្បីបង្ហាញពីស្ថានភាពរេដបូកនៅកម្ពុជា មុននឹងនិយាយពីគោលបំណងនៃយុទ្ធសាស្ត្រ។

លោក គឹម ណុង៖ គាំទ្រយោបល់ ឯ.ឧ នេត មុន្នី និងលោកបណ្ឌិត ដោក ដូម៉ា ឲ្យមានចំណុចលំអិតបន្ថែម និងការវិភាគពីបញ្ហាពាក់ព័ន្ធនឹងរេដបូកនៅកម្ពុជា។ លោកគិតថាការងាររៀបចំយុទ្ធសាស្ត្ររេដបូកជាតិជាកិច្ចការបច្ចេកទេស ប៉ុន្តែការអនុម័តយុទ្ធសាស្ត្ររេដបូកជាតិជាការសម្រេចកម្រិតគោលនយោបាយ។ ដូច្នេះយើងត្រូវគិតគូរពិចារណាពីការសម្រេចលើយុទ្ធសាស្ត្ររេដបូកជាតិ ដែលនឹងយកទៅបង្ហាញនៅកិច្ចប្រជុំ UNFCCC នៅ COPទី២១ សម្រាប់ឆ្នាំ២០១៥។ លោកបានជម្រាបថា រាជរដ្ឋាភិបាលបានគាំទ្រក្រសួងបរិស្ថានឲ្យធ្វើជាជនបង្គោលជាតិសម្រាប់រេដបូក។ បច្ចុប្បន្នក្រសួងបរិស្ថានកំពុងរៀបចំរចនាសម្ព័ន្ធថ្មី ប៉ុន្តែមិនទាន់ច្បាស់ទេថានរណាជាជនបង្គោលប្រហែលពីរខែខាងមុខទៀតទើបអាចដឹង។ ដូច្នេះនៅពេលដែលមានរចនាសម្ព័ន្ធ នឹងដឹងថានរណាជាជនបង្គោល យើងនឹងបន្តពិចារណាថាតើត្រូវធ្វើកិច្ចការងារផ្នែកគោលនយោបាយយ៉ាងដូចម្តេចទាក់ទងនឹងការរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះ។

ឯ.ឧ ជាម ប៉េអា៖ យើងមានក្រុមបច្ចេកទេស ប៉ុន្តែយើងមិនដឹងថាក្រុមបច្ចេកទេសទាំងនេះបានជជែកគ្នា ឬ បានអនុម័តហើយឬនៅ ទោះជាយ៉ាងណាយើងបានពិនិត្យឃើញថា សេចក្តីព្រាងជំពូកទាំង១២នេះមានការសិក្សាយកតាមស្តង់ដាប្រទេសផ្សេងៗ។ ការធ្វើយុទ្ធសាស្ត្រនេះ សូមកុំពឹងផ្អែកតែលើជំនួយរបស់ដៃគូ ព្រោះថាវានឹងមិនធានាសុវត្ថិភាពរេដបូករបស់យើងនោះទេ ដូច្នេះយើងគួរតែគិតពីទីផ្សាររបស់កាបូនរេដបូកផង។ ដូច្នេះយុទ្ធសាស្ត្ររេដបូកជាតិត្រូវមានប្រធានបទ ឬ ជំពូកជាក់លាក់ជាងនេះ។ ទាក់ទងនឹង

គោលការណ៍ តើយើងត្រូវមានក្របខ័ណ្ឌគតិយុត្តិគាំទ្រ។ ដូចលោក គឹម ណុង បានលើកឡើង យុទ្ធសាស្ត្ររេដបូកជាតិត្រូវយោងទៅលើច្បាប់។ ការបង្ហាញជំពូកទាំង១២ មានភាពខ្លីពេក មិនដឹងថានឹងមានអ្វីត្រូវដាក់បញ្ចូលទៅក្នុងចំណុចណា។ ពេលនេះយើងមិនអាចអនុម័តបានទេ ដូច្នេះសុំឲ្យលេខាធិការដ្ឋានធ្វើការជាមួយក្រុមបច្ចេកទេស ដើម្បីរៀបចំឲ្យបានលម្អិតជាងនេះ មុននឹងសុំការសម្រេចលើជំពូកនីមួយៗ។

លោក ងួន ភក្តី៖ ទាក់ទងនឹងការងារបច្ចេកទេស យើងបានលម្អិតលើជំពូកខ្លះៗហើយ ក្រោយពីបានសិក្សាបទពិសោធន៍ប្រទេសនានាដូចជា: វៀតណាម សាំបៀរ និងប្រទេសតាន់ហ្សានៀ ប៉ុន្តែមិនបានបង្ហាញនៅថ្ងៃនេះទេ។ ចំពោះព័ត៌មានលម្អិត យើងនឹងធ្វើការជាមួយនឹងក្រុមបច្ចេកទេសបន្តទៀត។ ការបង្ហាញថ្ងៃនេះ មានបំណងសុំក្រុមការងារពិនិត្យ និងផ្តល់យោបល់ទៅលើមាតិកា ដើម្បីលេខាធិកាដ្ឋានបន្តការងារ។ ដូច្នេះនៅក្នុងកិច្ចប្រជុំក្រុមការងារលើកក្រោយ នឹងមានមាតិកាលម្អិតជាងនេះ។ ការងារនេះមានលោក Tim Boyle, Peter, Hiroshi និងលោក ឈុន ឌីលុច ជួយសហការ និងផ្តល់យោបល់។ ចំពោះបញ្ហានៃរេដបូក ដូចលោកបណ្ឌិត ដោក ដូម៉ា បានលើកឡើងនឹងមានសរសេរនៅក្នុងគោលបំណងនៃយុទ្ធសាស្ត្រ ។

លោក អ៊ុក វិបុល៖ នៅក្នុងជំពូកទី១១ យើងគិតតែពីតួនាទីរបស់ថ្នាក់ក្រោមជាតិ ជាសំណូមពរត្រូវបញ្ចូលតួនាទីថ្នាក់ជាតិផងដែរ។ គួរកែសម្រួលចំណងជើងនៃជំពូកទី១១នេះ ដោយពិចារណាទៅលើពាក្យថាប្រព័ន្ធ ឬ យន្តការនៅក្នុងការអនុវត្តរេដបូក ជាជាងចំណងថាការអនុវត្តថ្នាក់ក្រោមជាតិ។

លោកបណ្ឌិត ដោក ដូម៉ា៖ លើកសំណួរថាតើឯកសារយុទ្ធសាស្ត្ររេដបូកជាតិនេះចាប់ផ្តើមដោយមិនមានសេចក្តីផ្តើមឬយ៉ាងណា? បញ្ហាជាសាកលជាទូទៅគេសរសេរនៅក្នុងសេចក្តីផ្តើម បុព្វបទជាទូទៅគេសរសេរនៅក្នុងសាវតាប្រទេស គេមិនអាចសរសេរនៅក្នុងគោលបំណងបាននោះទេ។

លោក ងួន ភក្តី៖ ប្រសិនបើក្រុមការងារសុំឲ្យមានការកែប្រែ និងដាក់បញ្ចូល យើងនឹងធ្វើការពិភាក្សាជាមួយនឹងក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់ ដើម្បីកែសម្រួល។

លោក កែវ អូម៉ាលីស្ស៖ សំណើដែលបានលើកឡើង លោកគិតថាអាចដាក់បញ្ចូលបាន ប៉ុន្តែវាអាស្រ័យលើទម្រង់នៃការសរសេរប៉ុណ្ណោះ។ អ្វីដែលសំខាន់លោកសុំឲ្យពិនិត្យសេចក្តីសម្រេច និងលក្ខខណ្ឌចាំបាច់នៅក្នុង COP ដែលយុទ្ធសាស្ត្ររេដបូកជាតិត្រូវតែបញ្ចូល ដូចជាប្រព័ន្ធត្រួតពិនិត្យ ជាតិ ប្រព័ន្ធបង្ហាញព័ត៌មានជាតិ។ ចំណុចសំខាន់មួយទៀត យុទ្ធសាស្ត្ររេដបូកជាតិត្រូវបញ្ចូលចំណុចដែលយើងបានធ្វើឲ្យស្របទៅតាមតម្រូវការរបស់ UN-REDD, UNFCC, FCPF ដូចជា UNDP តម្រូវឲ្យមានយន្តការដោះស្រាយទំនាស់ ដូច្នេះយើងត្រូវបន្ថែមលើចំណុចនេះ និង FCPF តម្រូវឲ្យមានបញ្ចូលពីបញ្ហាគ្រប់គ្រងប្រើប្រាស់ដី។ លើសពីនេះបើអាចបញ្ចូលបញ្ហាយេនឌ័របានជាការប្រសើ បំផុត។

ឯ.ឧ. ជា សំអាង៖ ចំណុចដែលបានលើកឡើងជាចំណុចល្អៗ ដែលយើងត្រូវពិចារណាសម្រាប់រៀបចំកិច្ចការនេះ។ ការបង្ហាញនេះគ្រាន់តែជាគ្រោងនៅឡើយ ដើម្បីសុំឲ្យក្រុមការងារជួយបំពេញបន្ថែមឲ្យបានគ្របដណ្តប់គ្រប់ចំណុចសំខាន់ៗ។ ការផ្តល់មតិទាំងអស់ នឹងត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ការផ្តល់មតិយោបល់ឲ្យមានសរសេរពីបញ្ហា គួរដាក់ក្នុងជំពូកមួយដោយឡែក។ ចំពោះការបង្ហាញឲ្យបានលម្អិត យើងនឹងធ្វើនៅពេលក្រោយ។ ចំពោះចំណុចទាក់ទងនឹងប្រព័ន្ធត្រួតពិនិត្យ គឺមានរួចហើយនៅក្នុង MRV ដោយឡែកបញ្ហាយេនឌ័រត្រូវពិចារណាថាតើគួរដាក់នៅក្នុងប្រព័ន្ធធានាសុវត្ថិភាព ឬ ក្នុង

មាតិកាដាច់ដោយឡែកណាមួយ។ ចំពោះការងារគោលនយោបាយ ជាការចាំបាច់ដែលត្រូវសម្រេចដោយរាជរដ្ឋាភិបាល ប៉ុន្តែមិនច្បាស់ថាតើ ទីស្តីការគណៈរដ្ឋមន្ត្រី ឬ ប្រមុខរាជរដ្ឋាភិបាលជាអ្នកសម្រេច។ ចំពោះដំណើរការទីប្រឹក្សានឹងរៀបចំសេចក្តីព្រាងលម្អិត និងពិភាក្សាឲ្យបានស៊ីជម្រៅ និងដោយមានការចូលរួមពីក្រុមបច្ចេកទេស។

លោក គឹម ណុងៈ ការអនុម័តអាចធ្វើតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែមធ្យោបាយមួយទៀតយើងអាចអនុម័តបានតាមគណៈកម្មការប្រែប្រួលអាកាសធាតុ ពីព្រោះវេជបូកស្ថិតក្រោមយន្តការគណៈកម្មការប្រែប្រួលអាកាសធាតុ។ ការអនុម័តតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ប្រើពេលវែង និងត្រូវគោរពទៅតាមគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិទៅតាមក្រុមអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ តែបើអនុម័តតាមគណៈកម្មាធិការប្រែប្រួលអាកាសធាតុ អាចមានភាពងាយស្រួលជាង។ យើងត្រូវគិតឲ្យហើយមុនពេលដែលយើងចាប់ផ្តើមដំណើរការ។

ឯ.ឧ. ជា សំអាងៈ ចំពោះការអនុម័ត យើងត្រូវពិនិត្យលើខ្លឹមសារ និងពិចារណាជាមួយថ្នាក់ដឹកនាំបន្ថែមទៀត ពីព្រោះកិច្ចការនេះមានពាក់ព័ន្ធនឹងស្ថាប័នផ្សេងៗទៀតដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃជាដើម។ នេះគ្រាន់តែជាការគិត តែការសម្រេចនឹងធ្វើនៅពេលក្រោយ។ ប្រសិនបើយើងមិនអាចបញ្ចប់ និងអនុម័តការងារនេះឲ្យបានទាន់ពេលវេលា យើងក៏អាចយកសេចក្តីព្រាងយុទ្ធសាស្ត្រវេជបូកជាតិ ទៅបង្ហាញនៅថ្នាក់អន្តរជាតិ ដើម្បីឲ្យគេបានដឹងថាយើងបានត្រៀមលក្ខណៈជាស្រេចក្នុងការអនុវត្តវេជបូក។

លោក ងួន ភក្តីៈ សេចក្តីព្រាងមាតិកាយុទ្ធសាស្ត្រវេជបូកជាតិលម្អិតជាងនេះ នឹងបង្ហាញជូនក្រុមការងារវេជបូកម្តងទៀតនៅកិច្ចប្រជុំលើកក្រោយ។ នៅក្នុងបទបង្ហាញនេះលោកអ៊ីវ៉ូស៊ីណាកាតា បានសុំឲ្យក្រុមការងារពិភាក្សាសំណួរពីរខាងក្រោមៈ

ថ្នាក់ដឹកនាំនៃបណ្តាប្រទេសជាភាគីនៃក្របខណ្ឌអនុសញ្ញាសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នឹងត្រូវបានអញ្ជើញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ឲ្យចូលរួមកិច្ចប្រជុំកំពូលស្តីពីអាកាសធាតុ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៤ នៅទីក្រុងញូយ៉កៈ

- តើសម្តេច ហ៊ុន សែន នឹងចូលរួមកិច្ចប្រជុំកំពូលនេះដែរឬទេ?
- បើសម្តេចចូលរួមតើក្រុមការងារវេជបូកនឹងស្នើសុំឲ្យសម្តេចលើកឡើងពីអ្វី?

ឯ.ឧ. ជា សំអាងៈ សំណួរទាំងពីរនេះ លោកសុំផ្អាកការគិត ព្រោះកម្ពុជាយើងមិនទាន់ដឹងថាថ្នាក់ដឹកនាំណានឹងអញ្ជើញចូលរួមនៅឡើយទេ ប៉ុន្តែយើងមានភារកិច្ចរៀបចំការងារសម្រាប់ថ្នាក់ដឹកនាំទៅចូលរួម។ ដូច្នេះយើងត្រូវរៀបចំសម្រាប់ថ្នាក់ដឹកនាំបានហើយ មិនចាំបាច់ត្រៀមសម្រាប់សម្តេចនោះទេ។ ចំពោះសំណួរនេះ យើងឆ្លើយមិនចេញទេពេលនេះ មានតែក្រុមរៀបចំយុទ្ធសាស្ត្រនេះហើយដែលត្រូវព្រាងនូវចម្លើយ ដើម្បីដាក់ឲ្យក្រុមការងារពិនិត្យ និងផ្តល់មតិយោបល់កែសម្រួល។

លោក កែវ អូម៉ាលីស្សៈ កិច្ចប្រជុំនៅទីក្រុងញូយ៉កកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រលើបញ្ហាវេជបូកនេះហើយ ប៉ុន្តែអ្វីដែលយើងគួរលេចនៅក្នុងកិច្ចប្រជុំ UNFCCC ឬ COPទី២០ ឬ COPទី២១ គឺការចរចារស្តីពីបញ្ហាថវិកាដែលមិនទាន់បានបញ្ចប់។



HY

ឯ.ឧ. ជា សំអាង៖ កិច្ចប្រជុំនៅទីក្រុងញូយ៉កធ្វើមុន COP ទី២០ ដែលពិភាក្សាលើនិន្នាការរួមជំរុញឲ្យមានរេដបូកជាសាកលនៅកម្រិតណាមួយ ពីព្រោះការពិភាក្សាកន្លងមកមិនទាន់បានសម្រេចជោគជ័យនៅឡើយ។ ដូច្នេះសុំឲ្យសមាជិកក្រុមការងារត្រៀមចម្លើយ ព្រោះសម្ដេចអាចនឹងសួរពីបញ្ហានេះ។ ការប្រជុំលើកនេះទំនងជាចង់ឲ្យបណ្ដាប្រទេសដែលចូលរួម ប្ដេជ្ញាចិត្តលើការងារអនុវត្ត មួយចំនួន ឲ្យបានប្រាកដ។ ចំពោះមតិលោក កែវ អូម៉ាលីស្ស យើងនឹងពិនិត្យមើលចំណុចសំខាន់ៗនៃការសម្រេចរបស់ UNFCCC ដើម្បីដាក់បញ្ចូលបន្ថែមទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ឯកឧត្តមសុំឲ្យ លោក ងួន ភក្តី បន្តទំនាក់ទំនងជាមួយលោក ភីតធី ដើម្បីរៀបចំសេចក្ដីព្រាងឯកសារទស្សនទាន(គោលគំនិត)សម្រាប់ថ្នាក់ដឹកនាំជាតិចូលរួមប្រជុំ ដោយសារកិច្ចប្រជុំនេះអាចនឹងតម្រូវឲ្យមានសេចក្ដីប្រកាសពីប្រទេសនីមួយៗ។

<u>**ការសម្រេច៖**</u>

- លោក ងួន ភក្តី ពិភាក្សាយោបល់ជាមួយក្រុមបច្ចេកទេសដើម្បីរៀបចំសេចក្ដីព្រាងមាតិកាយុទ្ធសាស្ត្ររេដបូកជាតិលម្អិតជាងមុន និងដាក់ជូនក្រុមការងាររេដបូកជាតិពិនិត្យ និងផ្ដល់យោបល់។
- លោក ងួន ភក្តី បន្តទំនាក់ទំនងជាមួយលោក ភីតធី ដើម្បីរៀបចំសេចក្ដីព្រាងឯកសារទស្សនទាន (គោលគំនិត)សម្រាប់ថ្នាក់ដឹកនាំជាតិចូលរួមប្រជុំ។

## ២.២. សំណើជម្រើសយន្តការសម្របសម្រួលគម្រោងរេដបូកនានា

លោក លន់ គឹមហ៊ី៖ បានបង្ហាញពីយន្តការសម្របសម្រួលដែលមានជម្រើសចំនួន៣៖ ១) សម្របសម្រួលគម្រោងនានាដែលកំពុងគាំទ្ររេដបូកនៅកម្ពុជា និងធ្វើរបាយការណ៍ជូនក្រុមការងារ ២)គម្រោងនានាដែលកំពុងគាំទ្ររេដបូកនៅកម្ពុជា ធ្វើបទបង្ហាញជូនក្រុមការងាររេដបូកកម្ពុជា ៣)កិច្ចប្រជុំរួមគ្នារវាងក្រុមការងាររេដបូកកម្ពុជា ជាមួយនឹងគម្រោងនានាដែលកំពុងគាំទ្ររេដបូកនៅកម្ពុជា។

<u>(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៥)</u>

<u>**ការពិភាក្សា៖**</u>

ឯ.ឧ. ជា សំអាង៖ គួរយកទាំងបីដោយអនុវត្តជម្រើសទាំងនេះតាមលំដាប់ជាបន្តបន្ទាប់ទៅតាមដំណាក់កាលនីមួយៗ។

លោកបណ្ឌិត កែវ អូម៉ាលីស្ស៖ ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិពឹងផ្អែកសំខាន់លើបទពិសោធន៍គម្រោងនានាដែលបានអនុវត្ត។ គម្រោងដែលអនុវត្តជាមួយរដ្ឋបាលព្រៃឈើ មន្ត្រីរាជរដ្ឋាភិបាលជាអ្នកអនុវត្ត ប៉ុន្តែតាមលោកដឹងគម្រោងដែលចុះកិច្ចសន្យាជាមួយក្រសួងបរិស្ថាន វិស័យឯកជនជាអ្នកអនុវត្តគម្រោង ដូច្នេះសុំឲ្យលេខាធិការដ្ឋានធ្វើការទំនាក់ទំនងជាមួយនឹងវិស័យឯកជនថាតើនឹងចូលរួមតាមយន្តការសម្របសម្រួលណាមួយ ដើម្បីយើងអាច ព្រោះថាវិស័យឯកជនទាំងនោះសុទ្ធជាអ្នកកម្រិតខ្ពស់ដែលមានការលំបាកក្នុងការទំនាក់ទំនង និងស្នើឲ្យមានការចូលរួម។

ឯ.ឧ. ជា សំអាង៖ វិស័យឯកជនយើងនឹងផ្ដល់ដល់គាត់ដោយមិនកំណត់ថាយកជម្រើសណាមួយឡើយ។ ការអនុវត្តគម្រោងទាំងនោះមិនទាន់ច្បាស់លាស់នៅឡើយទេ ដរាបណាយើងមានយុទ្ធសាស្ត្ររេដបូកជាតិទើប ការអនុវត្តគម្រោងមានភាពច្បាស់លាស់។

ឯ.ឧ នេត មុន្នីៈ គាំទ្រយោបល់ជ្រើសយកជម្រើសទាំងបី ប៉ុន្តែយើងត្រូវកំណត់ពេលវេលាឲ្យច្បាស់លាស់សម្រាប់ជម្រើសនីមួយៗជាការប្រសើ ដោយសារជម្រើសនីមួយៗមានសារសំខាន់ដូចគ្នា និងអាចធ្វើបានតាមស្ថានភាពនិងពេលវេលាខុសគ្នា។

ឯ.ឧ ជាម ប៉េអាៈ ឯកឧត្តមមិនច្បាស់ថា ជម្រើសទាំងបីធ្លាប់បានអនុវត្តដែរឬទេ? តើមានបញ្ហាកើតឡើងដែរឬយ៉ាងណា? ឬមួយគ្រាន់តែជាការគិតគូរពិចារណាដើម្បីគ្រប់គ្រង ឬគ្រាន់តែជាការសម្របសម្រួលដើម្បីប្រមូលព័ត៌មាន។ យើងជាស្ថាប័នដែលមានកាតព្វកិច្ចក្នុងការជម្រាបជូនទៅគណកម្មាធិការជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ព័ត៌មានដែលទទួលបានពីគម្រោងនានា ភាគច្រើនជាព័ត៌មានបច្ចេកទេស ដូច្នេះត្រូវកំណត់ឲ្យច្បាស់ថា តើកម្រិតណាជាកម្រិតបច្ចេកទេស? កម្រិតណាជាកម្រិតក្រុមការងារ? ជៀសវាងការច្របូកច្របល់ បើមិនដូច្នេះទេកំណត់ហេតុនៃកិច្ចប្រជុំយើងមិនអាចយកជាឯកសារយោងបានទេ។

ឯ.ប. ជា សំអាងៈ បញ្ជាក់បន្ថែមថាយោបល់ ឯ.ឧ នេត មុន្នី និងយោបល់ឯ.ឧ ជាម ប៉េអា ចង់ឲ្យលេខាធិការដ្ឋាន មានយន្តការលម្អិតសម្រាប់ការអនុវត្តជាលក្ខណៈប្រព័ន្ធ។ ឧទាហរណ៍: លេខាធិការដ្ឋានសម្របសម្រួលឲ្យមានកិច្ចប្រជុំគម្រោងនានា បន្ទាប់មករាយការណ៍ជូនក្រុមការងាររេដបូក ដោយអ្នករាយការណ៍ អាចជាតំណាងរបស់ពួកគាត់ ឬ លេខាធិការដ្ឋាន ទៅតាមប្រធានបទ និងស្ថានភាពជាក់ស្តែង។ ប្រសិនបើមានគម្រោងណាមួយចង់បង្ហាញពីលទ្ធផលបច្ចេកទេស និងបញ្ហាប្រឈម ជូនក្រុមការងារ ដើម្បីពិនិត្យ និងផ្តល់យោបល់ យើងអាចឲ្យគាត់ចូលរួមបានដែរ។ ម្យ៉ាងវិញទៀតបើគម្រោងនានាចង់ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ ដើម្បីបង្ហាញពីផែនការ លទ្ធផល និងបញ្ហារួមរបស់ពួកគាត់ ដើម្បីឲ្យក្រុមការងារផ្តល់យោបល់ យើងក៏អាចឲ្យគាត់ចូលរួមបានដែរ។ ជាទូទៅ ក្រុមការងាររេដបូកត្រូវមានព័ត៌មាន និងភ្ជាប់ឲ្យបាននូវគម្រោងរេដបូកទាំងអស់ ដើម្បីមានលទ្ធភាពផ្តល់យោបល់ធ្វើឲ្យការអនុវត្តកាន់តែមានភាពប្រសើរឡើង ព្រោះថាតទៅអនាគតនៃការអនុវត្តរេដត្រូវស្ថិតនៅក្រោមកម្មវិធីជាតិ។ យន្តការសម្របសម្រួលនេះនឹងអាចផ្លាស់ប្តូរកែសម្រួល តាមស្ថានភាពជាក់ស្តែងនាពេលអនាគត ដើម្បីធានាឲ្យមានប្រសិទ្ធិភាព។

ឯ.ឧ នេត មុន្នីៈ ស្នើយោបល់ថាយន្តការសម្របសម្រួលទាំងបីគួរដាក់ទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិដែរឬទេ ដើម្បីធានាឲ្យអ្នកពាក់ព័ន្ធអនុវត្តតាម ព្រោះថាយុទ្ធសាស្ត្ររេដបូកជាតិជាឯកសារមួយដែលតម្រូវឲ្យគ្រប់គ្នាអនុវត្តតាម។

ឯ.ប. ជា សំអាងៈ យើងនឹងមានដាក់ចូលនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិនៅផ្នែកតាមដាន ត្រួតពិនិត្យ និងប្រព័ន្ធធានាសុវត្ថិភាព ដែលអនុញ្ញាតិឲ្យមានការចូលរួមផ្តល់ និងទទួលព័ត៌មាន។ ដូច្នេះនៅក្នុងយុទ្ធសាស្ត្រនិងលម្អិតពីយន្តការសម្របសម្រួល និងការចែករំលែកព័ត៌មាន។

ឯ.ឧ ជាម ប៉េអាៈ ជូនយោបល់ថា ប្រសិនបើយន្តការសម្របសម្រួលនេះ មានបំណងប្រមូលគម្រោងទាំងអស់ចូលតាមច្រកតែមួយ យើងគួរតែជៀសវាង ព្រោះតាមបទពិសោធន៍របស់លេខាធិការដ្ឋាន គ.ជ.អ.ប (NCDD) ធ្លាប់បានព្យាយាមអនុវត្តយន្តការច្រកចេញចូលតែមួយ ប៉ុន្តែបានធ្វើឲ្យ គ.ជ.អ.ប មានដៃគូកាន់តែតិច ដោយហេតុថាគម្រោងភាគច្រើនចង់ឲ្យការអនុវត្តរបស់គាត់មានភាពបត់បែន និងឯករាជ។

ឯ.ប. ជា សំអាងៈ ឯកភាពតាមយោបល់ខាងលើ ព្រោះឯកឧត្តមក៏ធ្លាប់បានគិតពីយន្តការច្រកចេញចូលតែមួយសម្រាប់អនុវត្តលើវិស័យព្រៃឈើដែរ ប៉ុន្តែឯកឧត្តមយល់ឃើញថាមិនអាចទៅរួច ព្រោះដៃគូ

អភិវឌ្ឍន៍ មានគោលការណ៍ និងនិតិវិធីដោយឡែករបស់គេ។ ឯកឧត្តមបញ្ជាក់ថាយន្តការសម្របសម្រួលនេះ មិនមែនជាគោលការណ៍រួមសម្រាប់ដៃគូត្រូវតែអនុវត្តនោះទេ ប៉ុន្តែជាបណ្ដាញការងារដើម្បីចែករំលែកព័ត៌មានស្ដីពីផែនការ ការងារបច្ចេកទេស បទពិសោធន៍ និងបញ្ហាប្រឈម ដើម្បីចូលរួមដោះស្រាយទាំងអស់។

**<u>ការសម្រេច៖</u>**

- លេខាធិការដ្ឋានត្រូវពិចារណាអនុវត្តជម្រើសទាំងបីទៅតាមដំណាក់កាលនិងស្ថានភាពជាក់ស្តែង។

## ២.៣. ជំហានបន្ទាប់សម្រាប់មូលនិធិរេដបូក

លោក ឈុន ឌីលុចៈ បានបង្ហាញពីយន្តការថវិកាដែលមានជម្រើសចំនួន៤៖ ១)Multiple-donor REDD+ Trust Fund ២)រដ្ឋាភិបាលគ្រប់គ្រងមូលនិធិរេដបូកថ្នាក់ជាតិ ៣)អន្តរមូលនិធិរេដបូកដែលស្ថិតនៅក្រោមមូលនិធិអាកាសធាតុជាតិ ៤)រួមបញ្ចូលរេដបូកទៅក្នុងផ្នែកនីមួយនៃច្បាប់គ្រប់គ្រងមូលនិធិ និងសុំឲ្យក្រុមការងារផ្ដល់យោបល់ និងជ្រើសយកជម្រើសណាមួយដើម្បីសិក្សាបន្តលម្អិត។

<u>(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៦)</u>

**<u>ការពិភាក្សា៖</u>**

ឯ.ឧ នេត មុន្នី៖ លើកសំនួរទាក់ទងនឹង Trust Fund ថាតើថវិកាទាំងនេះលំហូរមកតែពីក្រៅប្រទេស ឬ មាននៅក្នុងប្រទេសដែរ? បើថវិកាមកពីក្រៅប្រទេសទំនងអាចទទួលយក ប៉ុន្តែយើងត្រូវពិភាក្សាបន្តទៀតថាការគ្រប់គ្រងដោយឯករាជនេះមានន័យកម្រិតណា។ បើពិនិត្យលើយន្តការដែលធ្លាប់មានកន្លងមក នៅពេលដែលមានអ្នកផ្ដល់ជំនួយផ្ដល់ថវិកាបន្ទាប់មកមានយន្តការគ្រប់គ្រងរួមគ្នារវាងអ្នកផ្ដល់ជំនួយនិងកម្ពុជាដោយមានការផ្ទេរថវិកាតាមរូបភាពជាក់ស្តែងណាមួយទៅតាមរូបមន្តនិងបទពិសោធន៍ដែលធ្លាប់បានធ្វើរួចហើយ។ ទាក់ទងនឹងថវិកាបានមកពីឥណទានកាបូនរាជរដ្ឋាភិបាលនឹងអាចបានចំណូលថវិកាពីឥណទានកាបូននេះតាមរយៈកិច្ចសន្យារវាងក្រសួងបរិស្ថានជាមួយក្រុមហ៊ុន Green Indo-China ដែលមានទឹកប្រាក់៦លានដុល្លា គឺជាចំណូលថវិកាជាតិដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លោក ឈុន ឌីលុចៈ ក្រោយពីបានពិនិត្យលើគោលនយោបាយដែលមានស្រាប់ទាំងថ្នាក់ជាតិ និងអន្តរជាតិ ជម្រើសទីមួយជាជម្រើសល្អជាងគេ ដោយសារបច្ចុប្បន្នមូលនិធិរេដបូកភាគច្រើន បានមកពីជំនួយអន្តរជាតិ។ ម្យ៉ាងវិញទៀតរហូតដល់ទៅ១០ឆ្នាំខាងមុខទៀត ទំនងជាមិនទាន់មានពីថវិកាជាតិសម្រាប់រេដបូកនៅឡើយទេ ដូច្នេះយន្តការដែលរៀបចំគួរផ្ដោតលើមូលនិធិអន្តរជាតិជាចម្បង ព្រោះថានៅពេលដែលយើងអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ យើងត្រូវការយន្តការថវិកាមួយច្បាស់លាស់ដើម្បីធានាថាជំនួយថវិកាដែលយើងទទួលបាន មានយន្តការប្រើប្រាស់ត្រឹមត្រូវ ដើម្បីគាំទ្រលើការចំណាយលើការងារអនុវត្ត។ ឆ្លើយតបនឹងសំណួរ ឯ.ឧ នេត មុន្នី ថាតើថវិកានេះគឺបានមកពីណា? អ្នកគ្រប់គ្រងឯករាជ្យមកពីណាខ្លះ? និងយន្តការគ្រប់គ្រងយ៉ាងដូចម្ដេច? លោក ឈុន ឌីលុច បញ្ជាក់ថានឹងអាចជម្រាបជូនបាន ប្រសិនបើក្រុមការងារអនុញ្ញាតិឲ្យលេខាធិការដ្ឋានបន្តការសិក្សាដោយលម្អិតលើជម្រើសទី១នេះ។

ឯ.ប. ជា សំអាង៖ ប្រសិនបើមិនអាចឆ្លើយបាននឹងសំណួរខាងលើ ក្រុមការងារមិនអាចសម្រេចចិត្តបានទេ សម្រាប់ជម្រើសទី១នេះ។ ឯកឧត្តមបានជម្រាបបន្ថែមថា តទៅមុខថវិការេដបូក ភាគច្រើននឹងបានមក

ពីម្ចាស់ជំនួយ ក៏ប៉ុន្តែនៅជំហានទី៣អាចនឹងមានចំណូលពីការលក់កាបូនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើយើងមានថវិកា១០លានដុល្លារ តើយើងគួរដាក់ចូលតាមច្រកណា ចាត់ចែងនិងគ្រប់គ្រងដូចម្តេចសម្រាប់គាំទ្រការអនុវត្តរេដបូក ដូច្នេះតម្រូវឲ្យមានយន្តការគ្រប់គ្រងថវិការេដបូកនេះ។ ចំពោះអ្នកគ្រប់គ្រងឯកវាជ្យ ជាទូទៅច្រើនធ្វើឡើងតាមរយៈដៃគូអភិវឌ្ឍ ជាជាងម្ចាស់ជំនួយ។

លោក លន់ គឹមហ៊ីះ បានបញ្ជាក់ថាការបង្ហាញនេះអាចជម្រាបជូនត្រឹមតែគោលការណ៍សំខាន់ៗនៃជម្រើសទាំងបួន ដើម្បីសុំការអនុញ្ញាតិបន្តការសិក្សាលើជម្រើសណាមួយប៉ុណ្ណោះ។

ឯ.ឧ នេត មុន្នីះ ប្រសិនបើដូច្នេះ យើងគួរចាត់អាទិភាពថាតើជម្រើសមួយណាដែលគួរសិក្សាបន្ត។

ឯ.ឧ ជាម ប៉េអា៖ ស្នើសុំឲ្យមានការយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ពាក្យពេចន៍ និងកែពាក្យរដ្ឋាភិបាល ទៅជារាជរដ្ឋាភិបាល។ ឯកឧត្តមជូនយោបល់ថាគួរបន្តការសិក្សាលម្អិតលើជម្រើសទាំងបួន និងរំលេចឲ្យឃើញពីគុណសម្បត្តិ និងគុណវិបត្តិ នៃជម្រើសទាំង៤ ដើម្បីងាយស្រួលក្នុងការសម្រេច។

លោកបណ្ឌិត កែវ អូម៉ាលីស្ស៖ សុំធ្វើការសិក្សាទៅលើជំនួយ និងចំណូលដែលនឹងទទួលបាន និងសិក្សាជម្រើសទាំងនេះឡើងវិញឲ្យបានលម្អិតទៅលើលំហូរថវិកា ដែលឆ្លើយតបនឹងចំណុចទាំងអស់នេះ។

ឯ.ប. ជា សំអាង៖ ពាក្យថា Trust Fund ភាគច្រើនគេប្រើប្រាស់សម្រាប់តែថវិកា ដែលម្ចាស់ជំនួយដាក់ផ្ញើប្រាក់នៅធនាគារ ដើម្បីយកការប្រាក់ផ្តល់ជាមូលនិធិជួយដល់អ្វីមួយ។ ឯកឧត្តមយល់ថាយន្តការថវិកាទី១ នេះអាចទំនងជា Multiple-donor REDD+ Fund អាចត្រឹមត្រូវជាង។

លោក គឹម ណុង៖ ជម្រើសទាំងនេះបានលើកឡើងដោយទីប្រឹក្សា ប៉ុន្តែមិនទាន់មានព័ត៌មានលម្អិតឲ្យយល់ច្បាស់ទេ។ យើងចង់ឲ្យមានយុទ្ធសាស្ត្ររេដបូកជាតិ ដូច្នេះទីប្រឹក្សាត្រូវសិក្សាលម្អិតឲ្យច្បាស់ថា ជាយុទ្ធសាស្ត្រយើងអាចទទួលបានថវិកាពីណា? បានដោយរបៀបណា? កន្លងមកបានមកពីណាខ្លះ? នៅពេលដែលមានថវិកា នោះយើងនឹងមានកិច្ចព្រមព្រៀង ឬ យន្តការច្បាប់ក្នុងការគ្រប់គ្រងថវិកានោះហើយ។ ដូច្នេះជាអាទិភាពលោកសុំឲ្យមានការសិក្សាលំអិតលើប្រភពចំណូលថវិកា។

**<u>ការសម្រេច៖</u>**

- សុំបន្តការសិក្សាលម្អិតលើជម្រើសនីមួយៗ និងដាក់បង្ហាញនៅក្នុងកិច្ចប្រជុំបន្ទាប់។

## ២.៤. ប្រព័ន្ធត្រួតពិនិត្យព្រៃឈើតាមផ្កាយរណប និងសំណើនិយមន័យព្រៃឈើជាតិ

លោក ឡេង ជីវិន បានបង្ហាញពី ប្រព័ន្ធត្រួតពិនិត្យដីតាមផ្កាយរណបដោយលើកឡើងពី ១)គោលគំនិតនៃការរៀបចំបង្កើត NFMS ២)ការពិចារណាទៅលើ Cambodian SLMS និង៣)សំណើនៃការត្រួតពិនិត្យដីធ្លីនៅកម្ពុជា។ ជាមួយគ្នានេះលោកបានបង្ហាញពីសំណើនិយមន័យព្រៃឈើជាតិ ដោយយោងទៅលើ ១)និយមន័យព្រៃឈើអន្តរជាតិ ២)និយមន័យព្រៃឈើជាតិដែលមានស្រាប់ និង៣)ការពិចារណាទៅលើជម្រើស។ លោក ឡេង ជីវិន បានបង្ហាញពីភាពខុសគ្នានៃការកំណត់និយមន័យព្រៃឈើ ដែលប្រែប្រួលទៅតាមបរិបទនៃប្រទេស ស្ថាប័ន ការគ្រប់គ្រង ពេលវេលា និងភាពស្មុគស្មាញក៏ដូចជាការប្រឈមនានាក្នុងការអនុវត្តកិច្ចការនេះ។

<u>(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៧)</u>

**ការពិភាក្សា៖**

ឯ.ឧ. ជា សំអាង៖ ការបង្ហាញនេះមានលក្ខណៈបច្ចេកទេសច្រើន ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ លោកមានបំណងជម្រាបជូនក្រុមការងារឲ្យបានជ្រាបពីការងារនេះ ជាពិសេសនិយមន័យព្រៃឈើ។ ការពិត យើងមាននិយមន័យព្រៃឈើដែលបានកំណត់ច្បាស់រួចហើយនៅក្នុងកម្មវិធីព្រៃឈើជាតិ ប៉ុន្តែយើងចង់បញ្ជាក់បន្ថែមលើដំណាំឈើមួយចំនួនដូចជាកៅស៊ូ ដូងប្រេង និងចំការឈើពាក់ព័ន្ធនឹងការអនុវត្តរេដបូក។

លោកបណ្ឌិត កែវ អូម៉ាលីស្ស៖ រេដបូកពាក់ព័ន្ធនឹងបញ្ហាធំ២ ១)ការបាត់បង់ព្រៃឈើ ២)ការរេចរឹលព្រៃឈើ លោកយល់ថាការកំណត់និយមន័យនេះអាចគណនាបានការបាត់បង់ព្រៃឈើ ប៉ុន្តែលោកមិនច្បាស់ថាតើការកំណត់និយមន័យនេះអាចគណនា ការរេចរឹលព្រៃឈើបានដែរឬទេ? ព្រោះថាគម្រោងនៅខេត្តឧត្តរមានជ័យ ដែលប្រើរូបភាពផ្កាយរណបមាន High Resolution បានបង្ហាញថាមានការសិករេចរឹលព្រៃឈើ ប៉ុន្តែក្រុមអ្នកវិភាគបញ្ជាក់ថាមិនអាចបញ្ចូលបាននោះទេ ដែលបញ្ហានេះបណ្តាលឲ្យការទូទាត់ថវិកាមានការខុសគ្នាដល់ទៅរាប់លានដុល្លារ។ ដូច្នេះលោកសុំឲ្យមានការប្រយ័ត្នប្រយែងក្នុងការកំណត់និយមន័យព្រៃឈើនេះ ពីព្រោះវាមានសារសំខាន់ក្នុងការវាស់វែងចំនួនកាបូនស្តុកព្រៃឈើ។

លោក ឡេង ជីវិន៖ យោបល់លោកបណ្ឌិត កែវ អូម៉ាលីស្ស បានលើកឡើងជាការត្រឹមត្រូវ។ តាមការសិក្សាលើបទពិសោធន៍របស់ប្រទេសមួយចំនួនដោយគិតួរពីការការសឹករេចរឹលព្រៃឈើ គេដាក់ High Resolution ទៅក្នុងនិយមន័យព្រៃឈើដែលបង្កើតថ្មី។ ប៉ុន្តែស្ថានភាពយើងការបង្កើតនិយមន័យព្រៃឈើថ្មីទំនងមិនអាចទៅរួច ដូច្នេះយើងបានធ្វើការកែសម្រួលឲ្យបានត្រូវខ្លះ ប៉ុន្តែមិនអាចត្រូវបានទាំងអស់ទេ។ម្យ៉ាងទៀតដោយគ្រាន់តែកែសម្រួលលើនិយមន័យដែលមានស្រាប់យើងអាចដំណើរការបានលឿនបើសិនបង្កើតថ្មីនោះនឹងមានការយឺតយ៉ាវ។

ឯ.ឧ. ជា សំអាង៖ សុំឲ្យពិនិត្យ និងគិតគូរពិចារណាឡើងវិញ ដើម្បីធានាថាអាចគ្របដណ្តប់បានគ្រប់ជ្រុងជ្រោយ ដោយមិនមានភាពខាតបង់។

**ការសម្រេច៖**

- សុំឲ្យពិនិត្យ និងគិតគូរពិចារណាឡើងវិញ ទៅលើនិយម និងការផ្តល់យោបល់ទាំងនេះ។

## ៣. បច្ចុប្បន្នភាពកម្មវិធីរេដបូកនៅកម្ពុជា

### ៣.១ បទពិសោធន៍លើផ្នែកយេនឌ័រ និងផែនការបង្កើតក្រុម

កញ្ញា ធី ហៀង៖ បានធ្វើបទបង្ហាញដោយសង្ខេបពីវឌ្ឍនភាពយេនឌ័ររេដនៅកម្ពុជាដែលឈានមុខជាងបណ្តាប្រទេសនានា និងទទួលបាននូវការចាប់អារម្មណ៍ និងគាំទ្រពីអង្គការអន្តរជាតិដែលចាប់អារម្មណ៍ លើការងារនេះ។ លើសពីនេះក៏បានបង្ហាញពីសេចក្តីព្រាងផែនការក្នុងការរៀបចំក្រុមយេនឌ័រដែលមានសមាជិក៨រូបជាមន្ត្រីមកពីស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធសំខាន់នឹងរេដបូក។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៩)

**ការពិភាក្សា៖**

ឯ.ប. ជា សំអាង៖ នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ នឹងមានបញ្ហាបការងារយេនឌ័រ។ គម្រោងបង្កើតក្រុមយេនឌ័រនឹងមានសមាជិក៨រូបជាមន្ត្រីមកពីស្ថាប័នរាជរដ្ឋាភិបាលមកពី រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។ ឯកឧត្តមស្នើសុំអង្គប្រជុំចូលរួមយោបល់ ឬ មានបំណងបញ្ចូលសមាជិកបន្ថែមទៀត។ ក្រុមយេនឌ័រនេះ ជាអ្នកជំនាញមានភារកិច្ចផ្តល់យោបល់លើការងាររេដពាក់ព័ន្ធនឹងយេនឌ័រ។ ដោយឡែកក្រុមសង្គមស៊ីវិល អាចបញ្ចូលអ្នកជំនាញទៅក្នុងក្រុមរបស់ខ្លួនដើម្បីធ្វើការពិភាក្សា និងផ្តល់ជាអនុសាសន៍លើបញ្ហាយេនឌ័រ។

**ការសម្រេច៖**

- សុំបន្តដំណើរការការងារនេះទៅតាមការសម្រេច និងគ្រោងទុកនេះ។

**បញ្ហាប្រឈមនៃក្រុមបច្ចេកទេស MRV/REL**

លោក ឃន សារ៉េត ៖ បានធ្វើបញ្ជាក់ថាក្រុមបច្ចេកទេស MRV ជាក្រុមសំខាន់ផ្តោតលើការងារបច្ចេកទេសសុទ្ធសាទ ដែលតម្រូវឲ្យមានផែនការសកម្មភាពជាក់លាក់ ដើម្បីបង្កើតលទ្ធផលបច្ចេកទេស។ យើងបានចំណាយពេលជិត៩ខែទម្រាំបង្កើតបានផែនការសកម្មភាព MRV ដូចបានចែកជូន។ បញ្ហាប្រឈមមានការយឺតយ៉ាងក្នុងការសម្រេចលទ្ធផល ដោយសារការចូលរួមដែលជាមន្ត្រីមកពីស្ថាប័នផ្សេងៗ លំបាកសម្របសម្រួលឲ្យមានការចូលរួមពេញលេញ។ ម្យ៉ាងវិញទៀត ក្រុមបច្ចេកទេស MRV ហាក់ដូចជានៅដាច់ដោយឡែក ដោយសារការចែករំលែកព័ត៌មាន និងការទំនាក់ទំនងជាមួយលេខាធិការដ្ឋាននៅមានកម្រិត ដែលសុំឲ្យមានការកែលម្អ ដើម្បីឲ្យការអនុវត្តទទួលបានលទ្ធផលល្អប្រសើរឡើង។ សមាជិកក្រុមបច្ចេកទេស MRV មកពីស្ថាប័នផ្សេងគ្នាមានជំនាញខុសគ្នា ពេលខ្លះស្តាប់គ្នាមិនបាន។ លើសពីនេះនៅពេលមានជំនួយបច្ចេកទេសពីបរទេស ការស្តាប់ និងការយល់មានកម្រិត ដោយសារសមត្ថភាពភាសាទន់ខ្សោយ។ បញ្ហាមួយទៀត ពេលរៀបចំបានឯកសារបច្ចេកទេស មិនដឹងសុំយោបល់ទៅខាងណាដែលជាថ្នាក់គ្រប់គ្រងផ្ទាល់។ ទិន្នន័យក៏នៅមានការខ្វះខាតច្រើន ដូច្នេះការធ្វើឲ្យបានសម្រេចយុទ្ធសាស្ត្ររេដបូកជាតិទាន់ពេលវេលាអាចមានការលំបាក។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ១៣)

**ការពិភាក្សា៖**

ឯ.ប. ជា សំអាង៖ សូរបញ្ជាក់ថាតើការបង្ហាញនេះចង់ឲ្យក្រុមការងារដោះស្រាយយ៉ាងដូចម្តេច?

លោក ឃន សារ៉េត៖ ដើម្បីឲ្យក្រុមបច្ចេកទេសដំណើរការការងារបានល្អសុំឲ្យមានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត (Incentive) សម្រាប់ក្រុម MRV មិនត្រឹមតែកាតទូរស័ព្ទទេ គួរមានចំណាយសោហ៊ុយធ្វើដំណើរផង។

ឯ.ប. ជា សំអាង៖ កាតទូរស័ព្ទអាចទទួលយកបាន ប៉ុន្តែសុំគាំទ្រចំណាយសោហ៊ុយធ្វើដំណើរ មិនអាចសម្រេចបានទេនៅពេលនេះ។ ដោយឡែកការងារជាក្រុមតែងមានការលំបាកដូចបានលើកឡើង ព្រោះថាសមាជិកកាន់តែច្រើនបញ្ហាក៏ច្រើនទៅតាមនោះដែរ នេះជាកត្តាសត្យានុម័ត ដូច្នេះយើងត្រូវមានការអត់ធ្មត់ និងយោគយល់ឲ្យបានច្រើន។ ឯកឧត្តមបញ្ជាក់ថា ការចូលរួមច្រើន ឬតិចមិនបញ្ហាឡើយ ៣នាក់ ឬម្នាក់

ឯងក៏អាចសម្រេចការបានដែរ ដោយគ្រាន់តែផលិតឯកសារ និងផ្ញើជូនសមាជិកអវត្តមានថាអង្គប្រជុំបានសម្រេចដូចនេះ បើគ្មានយោបល់ចាត់ទុកថាជាការសម្រេចគាំទ្រ។ ព្រោះថាជួនកាលសមាជិកក្រុមបច្ចេកទេសគាត់មានការរវល់ខ្លាំងមិនអាចចូលរួមបាន។ ដូច្នេះយើងជាជំនាញត្រូវមានការប្រឹងប្រែងទទួលខុសត្រូវសម្រេចការងារឲ្យបាន។

<u>ការសម្រេច៖</u>

- ការចូលរួមច្រើនឬតិចមិនបញ្ហាឡើយ តែត្រូវផលិតឯកសារ និងផ្ញើជូនសមាជិកអវត្តមាន ថាអង្គប្រជុំបានសម្រេចដូចនេះ បើគ្មានយោបល់ចាត់ទុកថាបានសម្រេចគាំទ្រ។

## ៤. *បញ្ហាផ្សេងៗ៖*

### ៤.១. អនុសាសន៍ក្រុមប្រឹក្សាយោបល់

ឯ.ឧ. ជា សំអាង៖ បានជម្រាបជូនអង្គប្រជុំថាក្រុមប្រឹក្សាយោបល់បាន ផ្តល់អនុសាសន៍លើប្រធានបទដែល លោក ងួន ភក្តី បានធ្វើបទបង្ហាញ ជាពិសេសសំណួរពីរដែលបានលើកឡើង។

<u>ការពិភាក្សា៖</u>

ឯ.ឧ. ជា សំអាង៖ មានយោបល់ថាក្រុមប្រឹក្សាយោបល់ គួរផ្តោតការយកចិត្តទុកដាក់ផ្តល់យោបល់តែលើបញ្ហា និងការងារបច្ចេកទេសរេដបូកជាការសមស្របនឹងអាណត្តិការងាររបស់ខ្លួន ប៉ុន្តែគួរផ្តោតលើការងារគោលនយោបាលរបស់រដ្ឋាភិបាលទេ។

លោកបណ្ឌិត កែវ អូម៉ាលីស្ស៖ សុំឲ្យតំណាងក្រុមប្រឹក្សាយោបល់ មកធ្វើបទបង្ហាញ ថាតើអនុសាសន៍នេះ ធ្វើតាមលក្ខខណ្ឌការងារ ឬ ផ្តោតទៅតាមម្ចាស់ជំនួយ?

លោក គឹម ណាង៖ សុំឲ្យក្រុមប្រឹក្សាយោបល់រេដបូក ផ្តល់អនុសាសន៍ លើការងារបច្ចេកទេសបានហើយ មិនផ្តោតទៅលើគោលនយោបាយ ឬ នយោបាយនោះទេ។ ការងារគាត់គួរផ្តល់យោបល់សំខាន់ទៅលើការងារក្រុមបច្ចេកទេស។

ឯ.ឧ នេត មុន្នី៖ ការផ្តល់យោបល់ជៀសមិនផុតពីបញ្ហានេះទេ ដូច្នេះយើងគ្រាន់តែសរសេរជាលិខិតមួយឆ្លើយតបទៅវិញ បញ្ជាក់ពីបញ្ហានេះទៅបានហើយ។

ឯ.ឧ. ជា សំអាង៖ លោកនឹងធ្វើការជាមួយលេខាធិការដ្ឋានក្នុងការដោះស្រាយ និងឆ្លើយតបទៅលើអនុសាសន៍ដែលបានផ្តល់មកនេះ។

<u>ការសម្រេច៖</u>

- ឯ.ឧ. ជា សំអាងនឹងធ្វើការជាមួយនឹងលេខាធិការដ្ឋានដើម្បីឆ្លើយតបទៅលើលិខិតនេះ។

### ៤.២. ការស្នើសុំប្រើប្រាស់ថវិកាដែលនៅសល់បន្តអនុវត្តផែនការសកម្មភាព MRV

លោក ម៉ាធូវ៉ាន់ជីន ៖ ស្នើសុំឲ្យក្រុមការងាររេដបូក ចេញលិខិតគាំទ្រការស្នើសុំបន្តប្រើប្រាស់ថវិកាដែលនៅសល់ដើម្បីបន្តអនុវត្តសកម្មភាពការងារ MRV។

<u>ការសម្រេច៖</u>

- ក្រុមការងារវេដបូកមិនអាចមានមូលដ្ឋានសម្រាប់ការគាំទ្រសំណើសុំបន្តប្រើប្រាស់ថវិកាដែលនៅសល់ដើម្បីអនុវត្តសកម្មភាពការងារ MRV បានឡើយ ដូច្នេះសុំឲ្យមានជាលិខិតស្នើសុំដោយមានភ្ជាប់ផែនការការងារដែលមានសកម្មភាព ពេលវេលា ថវិកា និងលទ្ធផលជាក់លាក់។

## មតិបូកសរុបពីអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាង ជាប្រធានអង្គប្រជុំ បានបូកសរុបនូវការសម្រេចសំខាន់ៗក្នុងកិច្ចប្រជុំរួមមាន៖

- លេខាធិការដ្ឋានត្រូវបន្តរកអ្នកបកប្រែឯកសារសេចក្តីសម្រេចCOP។
- បន្តចរចារជាមួយនឹង UNDP លើបញ្ហាអត្រា DSA ។
- លោក ងួន ភក្តី ពិភាក្សាជាមួយក្រុមបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រវេដបូកជាតិលម្អិតជាងមុន ដាក់ជូនក្រុមការងារវេដបូកជាតិពិនិត្យ និងផ្តល់យោបល់។
- លោក ងួន ភក្តី ទំនាក់ទំនងជាមួយលោក ភីតធី ដើម្បីរៀបចំសេចក្តីព្រាងឯកសារទស្សនទាន(គោលគំនិត)សម្រាប់ថ្នាក់ដឹកនាំជាតិចូលរួមប្រជុំនៅញ៉ូយ៉ក។
- លេខាធិការដ្ឋានពិចារណាអនុវត្តជម្រើសយន្តការសម្របសម្រួលទាំងបីទៅតាមដំណាក់ណានីមួយៗ។
- លោក ឈុន ឌីលុច បន្តសិក្សាទៅលើជម្រើសយន្តការថវិកាវេដបូកទាំង៥ឲ្យបានលម្អិត និងដាក់ជូនក្រុមការងារវេដបូកជាតិពិនិត្យ និងផ្តល់យោបល់។
- លោក ឡេង ជីវិន ពិនិត្យ និងពិចារណាឡើងវិញ ទៅលើនិយមន័យព្រៃឈើ និងការផ្តល់យោបល់ទាំងនេះ។
- កញ្ញា ធី ហៀង បន្តការងារបង្កើតក្រុមយេនឌ័រ តាមការសម្រេច និងការគ្រោងទុក។
- ឲ្យធ្វើការទៅតាមការចូលរួម ប្រសិនបើមានការចូលរួមតិច គឺសម្រេចទៅតាមចំនួននៃការចូលរួម។
- ការចូលរួមច្រើនឬតិចមិនបញ្ហាឡើយ តែត្រូវផលិតឯកសារ និងផ្ញើជូនសមាជិកអវត្តមាន ថាអង្គប្រជុំបានសម្រេចដូចនេះ បើគ្មានយោបល់ចាត់ទុកថាបានសម្រេចគាំទ្រ
- ឯ.ឧ. ជា សំអាងនឹងធ្វើការជាមួយនឹងលេខាធិការដ្ឋានដើម្បីឆ្លើយតបអនុសាសន៍ក្រុមប្រឹក្សាយោបល់។
- សុំឲ្យមានជាលិខិតស្នើសុំ ដោយមានភ្ជាប់ផែនការការងារដែលមានសកម្មភាព ពេលវេលា ថវិកា និងលទ្ធផលជាក់លាក់ ស្តីពីសំណើសុំបន្តប្រើប្រាស់ថវិកាដែលនៅសល់ដើម្បីអនុវត្តសកម្មភាពការងារ MRV ។

ចុងបញ្ចប់ឯកឧត្តមបណ្ឌិតប្រធានអង្គប្រជុំ បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ ដែលបានចូលរួមមតិយោបល់ និងអនុសាសន៍ និងលេខាធិការដ្ឋានវេដបូក ចំពោះសម្របសម្រួលលើការងារ និង

សុំឲ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពឲ្យបានប្រសើរឡើងនៅកិច្ចប្រជុំបន្ទាប់។ សូមជូនពរក្រុមការងារសម្រេចការងារឲ្យបានជោគជ័យ។

កិច្ចប្រជុំលើកទី៦ នឹងជូនដំណឹងនៅពេលក្រោយ។ ៕

អ្នកធ្វើកំណត់ហេតុ

For

Lun. kimhy

ប្រធានអង្គប្រជុំ
បានឃើញ និងឯកភាព

កញ្ញា ធី ហៀង
មន្ត្រីទំនាក់ទំនងលេខាធិការដ្ឋានវេជបូកកម្ពុជា